(៤៥)

# សារាចរស្តីពី

# យន្តការដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្ត
# សកម្មភាពការងារកែទម្រង់ការគ្រប់គ្រង
# ហិរញ្ញវត្ថុសាធារណៈ

លេខ: ០០៦ សហវ

ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០២......សហវ.....

# សារាចរ
## ស្តីពី
## យន្តការដោះស្រាយបញ្ហាប្រឈម
## ក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បាននិងកំពុងឈានមកដល់ដំណាក់កាលនៃការផ្លាស់ប្តូរដ៏សំខាន់ ទាំងរចនាសម្ព័ន្ធដឹកនាំនិងគ្រប់គ្រង ទាំងយន្តការនិងនីតិវិធីនៃកិច្ចដំណើរការ ជាពិសេសតាមរយៈការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ ចាប់ពីឆ្នាំ២០១៥ តទៅ។ ការផ្លាស់ប្តូរនានានៅក្នុងដំណាក់កាលនេះ បានបង្កើតឱ្យមានបញ្ហាប្រឈមមួយចំនួន ដែលទាមទារឱ្យមានការពិនិត្យ តាមដាន និងយកចិត្តទុកដាក់ខ្ពស់ ក្នុងការកំណត់បញ្ហាប្រឈមឱ្យបានជាក់លាក់ និងចាត់វិធានការណ៍ដោះស្រាយជាបន្ទាន់ សំដៅធានាជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យមានវឌ្ឍនភាព ប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព។

នៅក្នុងបរិការណ៍នេះ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) សម្រេចដាក់ចេញនូវយន្តការដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចតទៅ ÷

### ក. យន្តការសម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បញ្ហាប្រឈមនានា រួមទាំងភាពមិនច្បាស់លាស់ ឬអសង្គតិភាពនៃការបកស្រាយ និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ការអនុវត្តថវិកាកម្មវិធី នៅក្នុងក្របខណ្ឌនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជានៅក្រសួង ស្ថាប័ន ទាំងឡាយដែលអនុវត្តថវិកាកម្មវិធីពេញលេញ ត្រូវកំណត់ឱ្យបានជាក់លាក់ និងពិនិត្យដោះស្រាយ ជាជំហានបឋម ដោយអគ្គនាយកដ្ឋានឬអង្គភាពជំនាញពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ឬមានការណែនាំបញ្ជាក់បន្ថែម តាមការចាំបាច់ ពីរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ដែលទទួលបន្ទុកអគ្គនាយកដ្ឋាន ឬអង្គភាពជំនាញពាក់ព័ន្ធនោះ។

ក្នុងករណីដែលបញ្ហាទាំងនោះ នៅតែពុំអាចដោះស្រាយបាន ក្នុងជំហានបឋម អគ្គនាយកដ្ឋាន ឬអង្គភាពជំនាញពាក់ព័ន្ធ ត្រូវរៀបចំលិខិតស្នើសុំការពិនិត្យនិងដោះស្រាយ មកអគ្គលេខាធិការដ្ឋាន នៃ.គ.ហ.ស. (អ.គ.ហ.) ដោយកំណត់និងគូសបញ្ជាក់អំពីកម្មវត្ថុនៃចំណោទបញ្ហា និងមូលហេតុ/ប្រភពនៃបញ្ហាប្រឈម ឱ្យបានច្បាស់លាស់ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ក្នុងករណីដែលបញ្ហាប្រឈម ដែលបានលើកឡើង មានលក្ខណៈមិនទាន់ជាក់លាក់ អ.គ.ហ. អាចចាត់បញ្ជូនមន្ត្រីជំនាញរបស់ខ្លួន ទៅពិនិត្យ និងសិក្សាបន្ថែម តាមការចាំបាច់ នៅសាមីអគ្គនាយកដ្ឋានឬអង្គភាពជំនាញ ឬអញ្ជើញថ្នាក់ដឹកនាំ ឬមន្ត្រីជំនាញ នៃអគ្គនាយកដ្ឋានឬអង្គភាពជំនាញពាក់ព័ន្ធ ចូលរួមប្រជុំ ដើម្បីពិនិត្យនិងដោះស្រាយ។

អ.គ.ហ. ត្រូវពិនិត្យនិងដោះស្រាយ តាមរយៈលិខិតឆ្លើយតប ទៅកាន់អគ្គនាយកដ្ឋាន ឬអង្គភាពជំនាញពាក់ព័ន្ធ ក្នុងរយៈពេលដ៏ខ្លីបំផុត ដោយឆ្លងជូន ប្រធាន គ.ហ.ស. ជ្រាបជារបាយការណ៍។

ប្រសិនបើបញ្ហាប្រឈម[illegible] អាចដោះស្រាយបានក្នុងកម្រិតជំនាញ អ.គ.ហ. ត្រូវស្នើសុំការពិនិត្យនិងសម្រេចជាគោលការណ៍លើដំណោះស្រាយ ពីប្រធាន គ.ហ.ស. ក្រោយពេលលើកឡើងនូវសំណើជម្រើសជាក់លាក់នៃគោលការណ៍ដំណោះស្រាយនីមួយៗ ដោយបញ្ជាក់អំពីមូលហេតុ និងផលវិបាកពាក់ព័ន្ធ។

ការសម្រេចរបស់ប្រធាន គ.ហ.ស. នឹងត្រូវរៀបចំនិងដាក់ឱ្យអនុវត្ត ក្នុងក្របខណ្ឌនៃសមត្ថកិច្ចរបស់ប្រធាន គ.ហ.ស. និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមាន អ.គ.ហ. ជាលេខាធិការ។

ការសម្រេចជាគោលការណ៍ដំណោះស្រាយ ក្រោមទម្រង់ជាលាយលក្ខណ៍អក្សរឬឯកសារផ្លូវការ ដោយ គ.ហ.ស. ត្រូវផ្សព្វផ្សាយ និងណែនាំអនុវត្ត ដោយទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាព ដោយ អ.គ.ហ. ដែលត្រូវរាយការណ៍ជូនប្រធាន គ.ហ.ស. តាមកាលកំណត់ជាទៀងទាត់។

ខ. យន្តការសម្រាប់ក្រសួង ស្ថាប័ន

ក្រសួង ស្ថាប័ន ទាំងឡាយណាដែលជួបប្រទះបញ្ហាប្រឈមនានាដែលកើតចេញពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសការអនុវត្តថវិកាកម្មវិធីពេញលេញ ត្រូវរៀបចំលិខិតស្នើសុំការពិនិត្យនិងដោះស្រាយ មក អ.គ.ហ. តាមរយៈក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ក.ហ.ស.) របស់សាមីក្រសួង ស្ថាប័ន ដោយកំណត់និងគូសបញ្ជាក់អំពីកម្មវត្ថុនៃចំណោទបញ្ហា និងមូលហេតុ/ប្រភពនៃបញ្ហាប្រឈមឱ្យបានច្បាស់លាស់ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

អ.គ.ហ. ត្រូវពិនិត្យនិងប្ញូកសុំរបស់ឡើសុំដោះស្រាយបញ្ហាប្រឈមទាំងនោះ និងបញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំប្រចាំខែរបស់ អ.គ.ហ.ជាមួយ ក.ហ.ស. នៃក្រសួង ស្ថាប័ន ដើម្បីពិភាក្សានិងដោះស្រាយ ដោយមានការចូលរួមពីអគ្គនាយកដ្ឋានឬអង្គភាពជំនាញពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បញ្ហាប្រឈមទាំងឡាយ ដែលត្រូវបានសម្របសម្រួលនិងដោះស្រាយដោយ អ.គ.ហ. ត្រូវរាយការណ៍ជូនប្រធាន គ.ហ.ស.។

បញ្ហាប្រឈមទាំងឡាយដែលត្រូវបានលើកឡើងដោយ ក.ហ.ស. នៃក្រសួង ស្ថាប័ន និងពុំអាចដោះស្រាយបានក្នុងកម្រិត អ.គ.ហ. ត្រូវលើកយកមកដោះស្រាយ នៅក្នុងយន្តការសម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងចំណុច ក. ខាងលើ។

ទទួលបានការជូនដំណឹងនេះ គ្រប់ក្រសួង ស្ថាប័ន គ្រប់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន ត្រូវអនុវត្តប្រកបដោយស័ក្តិសិទ្ធភាព ប្រសិទ្ធភាព ភាពជាម្ចាស់ និងស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
និងជាប្រធានគណៈកម្មាធិការដឹកនាំការងារ
កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

កន្លែងទទួល ÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ